# ព្រហ្មទត្តជាតក



*ព្រះសាស្តា កាលស្តេចគង់នៅអគ្គាឡវចេតិយ ដែលអាស្រ័យនៅនឹងក្រុងអាឡវី ទ្រង់ប្រារព្ធ**កុដិការសិក្ខាបទ**[១] (វិនយបិដក សង្ឃាទិសេសកណ្ឌ បិដកលេខ ២ សិក្ខាបទនេះសម្តែងពីការសូម)* បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ទ្វយំ យាចនកោ** ដូច្នេះជាដើម ។

*១. កាលនោះ ពួកភិក្ខុនៅក្នុងដែនអាឡវី ប្រើគេឲ្យសាងនូវកុដិ ដែលមានគ្រឿងឧបករណ៍សម្រាប់សង់ សូមពីគេមកខ្លួនឯង ឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ធំហួសប្រមាណ ។ កុដិទាំងនោះមិនទាន់សម្រេច ។ ភិក្ខុទាំងនោះក៏ចេះតែសូមញឹកៗ ញយៗ ដោយពាក្យសូមថា អ្នកទាំងឡាយ ចូរឲ្យបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោ ឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក ឲ្យវល្លិ ឲ្យឫស្សី ឲ្យស្មៅយ៉ាប្លង ឲ្យស្មៅដំណេកទន្សាយ ឲ្យស្មៅ ឲ្យដីស្អិតដល់អាត្មា ។ ពួកមនុស្សដែលភិក្ខុទាំងនោះចេះតែបៀតបៀន ដោយការសូមញឹកញយហួសពេក លុះដល់ឃើញពួកភិក្ខុហើយ ក៏ភ្ញាក់ផ្អើល តក់ស្លុត លបរត់គេចទៅទីដទៃ បែរមុខទៅទីដទៃ បិទទ្វារផ្ទះ សូម្បីគ្រាន់តែឃើញនូវគោញីក៏គេចរត់ដោយស្មានថាជាពួកភិក្ខុ ។*

រឿងរ៉ាវ (បច្ចុប្បន្នជាតកនេះ) មានមកហើយក្នុង **មណិកណ្ឋជាតក** (តិកនិបាត សង្កប្បវគ្គ) ។ ចំណែកក្នុងជាតកនេះ ព្រះសាស្តាត្រាស់ (សួរ) ថា

ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយប្រព្រឹត្តសូមច្រើន ប្រព្រឹត្តវិញ្ញត្តិច្រើនឬ?

កាលពួកភិក្ខុទូលថា ពិតមែនហើយព្រះអង្គ ព្រះសាស្តាតិះដៀលភិក្ខុទាំងនោះ ហើយត្រាស់ទៀតថា ម្នាលភិក្ខុទាំងឡាយ បោរាណបណ្ឌិតទាំងឡាយ សូម្បីព្រះរាជាដែលជាធំលើផែនដីបវារណា ជាអ្នកប្រាថ្នានឹងសូមកម្រាលមានរូបផ្កាឈើជាប់គ្នាមួយ និងស្បែកជើងមួយគូ ក៏មិនពោល (សូម) ក្នុងកណ្តាលមហាជនដែរ (សុខចិត្ត) ពោល (សូម) ក្នុងទីស្ងាត់កំបាំង ដូច្នេះហើយ ព្រះអង្គទើបនាំអតីតនិទានមកថា ៖

ក្នុងអតីតកាល កាលព្រះបាទឧត្តរបញ្ចាល សោយរាជសម្បត្តិក្នុងឧត្តរបញ្ចាលនគរ ដែនកបិលរដ្ឋ ព្រះពោធិសត្វកើតក្នុងព្រាហ្មណត្រកូល ក្នុងនិគមគ្រាមមួយ កាលចម្រើនវ័យធំហើយ បានសិក្សារៀនសូត្រសព្វវិជ្ជាក្នុងនគរតក្កសិលា កាលបន្តបន្ទាប់មក លោកបួសជាតាបស ចិញ្ចឹមជីវិតដោយការស្វែងរកមូលផលាផលក្នុងព្រៃ រស់នៅអស់កាលដ៏យូរ ក្នុងព្រៃហិមពាន្ត ហើយត្រាច់ទៅកាន់ផ្លូវមនុស្ស ដើម្បីត្រូវការសេពរសប្រៃនិងជូរ ក៏ទៅដល់ឧត្តរ-បញ្ចាលនគរ ហើយស្នាក់នៅក្នុងរាជឧទ្យាន ក្នុងថ្ងៃស្អែក កាលស្វែងរកភិក្ខា លោកក៏ចូលទៅកាន់នគរ រហូតដល់រាជទ្វារ ។ ព្រះរាជាជ្រះថ្លានឹងអាចារៈ និងវិហារធម៌របស់តាបសនោះ ក៏និមន្តឲ្យគង់ក្នុងមហាពោង និងឲ្យតាបសឆាន់បណីតភោជន ដែលសមគួរដល់ព្រះរាជា ហើយឲ្យកាន់យកបដិញ្ញា ឲ្យតាបសនៅក្នុងរាជឧទ្យាននោះឯង ។ តាបសឆាន់ក្នុងព្រះរាជវាំងអស់កាលជានិច្ចហើយ ដោយកាលកន្លងទៅនៃវស្សានរដូវ លោកមានសេចក្តីប្រាថ្នានឹងទៅ

ព្រៃហិមពាន្តវិញ ទើបគិតថា យើងកាលដើរទៅ គួរនឹងបានកម្រាលមានរូបផ្កាឈើជាប់គ្នាមួយ ស្បែកជើង និងឆត្រស្លឹកឈើ យើងនឹងសូមព្រះរាជា ។

ថ្ងៃមួយ តាបសឃើញព្រះរាជា ដែលយាងមករាជឧទ្យាន ថ្វាយបង្គំ ប្រថាប់ហើយ ក៏គិតថា យើងនឹងសូមស្បែកជើង និងឆត្រ ហើយគិតទៀតថា បុគ្គលកាលសូមអ្នកដទៃថា លោកចូរឲ្យវត្ថុនេះ ដូច្នេះឈ្មោះថា យំ, សូម្បីអ្នកដទៃកាលពោលថា មិនមាន ដូច្នេះក៏ឈ្មោះថា យំតប, មហាជនកុំបានឃើញយើងយំ និងកុំឃើញព្រះរាជាយំតបឡើយ ដូច្នេះសូម្បីយើងទាំងពីរត្រូវយំក្នុងទីស្ងាត់កំបាំង យើងនឹងនៅស្ងៀមសិន ។

ពេលនោះ តាបសពោលនឹងព្រះរាជាថា បពិត្រមហារាជ អាត្មាភាពប្រាថ្នាទីស្ងាត់ ។

ព្រះរាជាស្តាប់ពាក្យនោះហើយបញ្ជាឲ្យរាជបុរសថយចេញ ។

ព្រះពោធិសត្វគិតថា ប្រសិនបើ យើងទូលសូមហើយ ព្រះរាជាមិនប្រទាន មេត្រីភាពរបស់យើងនឹងបែក ព្រោះហេតុនោះ យើងនឹងមិនសូម ដូច្នេះហើយ កាលមិនអាចនឹងកាន់យកឈ្មោះថ្ងៃនោះ ទើបពោលថា បពិត្រមហារាជ សូមទ្រង់ទៅមុនចុះ ថ្ងៃស្អែក អាត្មានឹងដឹង ។

ថ្ងៃស្អែក កាលព្រះរាជាយាងមកឧទ្យាន ព្រះពោធិសត្វក៏ពោលយ៉ាងនោះទៀត កាលមិនអាចនឹងទូលសូម បែបនេះ កន្លងពេលទៅ អស់ ១២ ឆ្នាំ ។ បន្ទាប់មក ព្រះរាជាគិតថា លោកម្ចាស់ពោលនឹងយើងថា បពិត្រមហារាជ អាត្មាភាពប្រាថ្នាទីស្ងាត់ កាលបរិស័ទចេញទៅ លោកមិនហ៊ាននិយាយអ្វីឡើយ លោកប្រាថ្នានឹងពោល ញ៉ាំងកាល ១២ ឆ្នាំឲ្យកន្លងទៅ លោកប្រព្រឹត្តព្រហ្មចរិយៈមកយូរហើយ ប្រហែលជាអផ្សុក ប្រាថ្នានឹងបរិភោគភោគសម្បត្តិ (ឬ) ប្រាថ្នារាជសម្បត្តិទេដឹង កាលមិនអាចនឹងកាន់យកឈ្មោះរាជសម្បត្តិ ទើបជាអ្នកនៅស្ងៀម ថ្ងៃនេះ យើងធ្វើចាប់ពីរាជសម្បត្តិជាដើម លោកប្រាថ្នាវត្ថុណា យើងនឹងឲ្យវត្ថុនោះ ។

ព្រះរាជាយាងទៅឧទ្យាន ថ្វាយបង្គំព្រះមហាសត្វ ហើយប្រថាប់ កាលព្រះពោធិសត្វពោលថា អាត្មាត្រូវការទីស្ងាត់ និងពេលដែលបរិស័ទចេញទៅហើយ ព្រះរាជាក៏ត្រាស់នឹងព្រះពោធិសត្វដែលជាអ្នកមិនហ៊ានពោលអ្វី ថា លោកម្ចាស់ពោលថា អាត្មាភាពប្រាថ្នាទីស្ងាត់ (យ៉ាងនេះ) អស់ ១២ ឆ្នាំហើយ សូម្បីបានទីស្ងាត់ លោកម្ចាស់ក៏នៅតែមិនហ៊ានពោលអ្វីឡើយ ខ្ញុំករុណាធ្វើរាជសម្បត្តិឲ្យជាខាងដើម សូមបវារណាវត្ថុទាំងពួង លោកម្ចាស់ចូរជាអ្នកមិនមានភ័យ ពេញចិត្តវត្ថុណារបស់ខ្ញុំករុណា លោកម្ចាស់ចូរសូមវត្ថុនោះចុះ ។

ព្រះពោធិសត្វសួរថា បពិត្រមហារាជ អាត្មាសូមវត្ថុណា ព្រះអង្គប្រទានវត្ថុនោះឬ?

ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ យើងនឹងឲ្យ ។

ព្រះពោធិសត្វពោលថា បពិត្រមហារាជ អាត្មាដើរផ្លូវទៅ គួរនឹងបានកម្រាលមានរូបផ្កាឈើជាប់គ្នាមួយ ស្បែកជើង និងឆត្រស្លឹកឈើ ។

ព្រះរាជាសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់មិនអាចនឹងសូមវត្ថុត្រឹមតែប៉ុណ្ណោះ អស់កាល ១២ ឆ្នាំឬ?

ព្រះពោធិសត្វទូលថា ពិតមែនហើយ មហារាជ ។

ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើបលោកធ្វើយ៉ាងនេះ?

ព្រះមហាសត្វទូលថា បពិត្រមហារាជ បុគ្គលកាលសូមថា អ្នកចូរឲ្យវត្ថុនេះ រមែងមានឈ្មោះថា យំ, បុគ្គលកាលពោលថា មិនមាន រមែងមានឈ្មោះថា យំតប, អាត្មាគិតថា ប្រសិនបើ កាលអាត្មាសូមហើយព្រះអង្គមិនប្រទាន រមែងបានឈ្មោះថា អាត្មានិងព្រះអង្គយំ

បើចឹងកុំឲ្យមហាជន ឃើញការយំរបស់ពួកយើង ដូច្នេះទើបអាត្មាត្រូវការទីស្ងាត់ ដើម្បីប្រយោជន៍ដល់វត្ថុនោះ ដូច្នេះហើយលោកក៏ពោល ៣ គាថាខាងដើមថា

ទ្វយំ យាចនកោ រាជ, ព្រហ្មទត្ត និគច្ឆតិ;
អលាភំ ធនលាភំ វា, ឯវំធម្មា ហិ យាចនា។

បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសូម រមែងបានផលពីរយ៉ាង គឺការមិនបានទ្រព្យ ១ ការបានទ្រព្យ ១ ព្រោះថា ការសូមមានយ៉ាងនេះជាធម្មតា ។

យាចនំ រោទនំ អាហុ, បញ្ចាលានំ រថេសភ;
យោ យាចនំ បច្ចក្ខាតិ, តមាហុ បដិរោទនំ។

បពិត្រព្រះអង្គជាឥស្សរៈលើរថនៃដែនបញ្ចាល អ្នកប្រាជ្ញទាំងឡាយ បានពោលនូវការសូមថាជាការយំ បុគ្គលណាឃាត់នូវការសូម អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះ ថាជាអ្នកមានការយំតប ។

មា មទ្ទសំសុ រោទន្តំ, បញ្ចាលា សុសមាគតា;
តុវំ វា បដិរោទន្តំ, តស្មា ឥច្ឆាមហំ រហោ។

កុំឲ្យពួកជនអ្នកដែនបញ្ចាលមកប្រជុំគ្នា ឃើញអាត្មាភាពកំពុងយំ ឬព្រះអង្គកំពុងយំតបឡើយ ព្រោះហេតុនោះ បានជាអាត្មាភាពត្រូវការទីស្ងាត់ ។

ព្រះរាជាជ្រះថ្លានឹងលក្ខណៈគារវៈ របស់ព្រះពោធិសត្វ កាលនឹងប្រទានពរ ទើបត្រាស់គាថាទី ៤ ថា

ទទាមិ តេ ព្រាហ្មណ រោហិណីនំ, គវំ សហស្សំ សហ បុង្គវេន;

**អរិយោ ហិ អរិយស្ស គាថំ ន ឧជ្ឈា, សុត្វាន គាថា តវ ធម្មយុត្តា។**

*បពិត្រព្រាហ្មណ៍ ខ្ញុំនឹងឲ្យគោញីសម្បុរក្រហម ១០០០ ព្រមទាំងគោឈ្មោលដល់លោក ព្រោះថាអរិយជន បានស្តាប់នូវគាថាប្រកបដោយធម៌ របស់លោកជាអរិយៈ មិនគប្បីឲ្យដូចម្តេចកើត ។*

*ពាក្យថា **លោកជាអរិយៈ** បានដល់ អ្នកដល់ព្រមដោយអាចារៈ ។ ពាក្យថា **គាថាប្រកបដោយធម៌** បានដល់ គាថាប្រកបដោយហេតុ ។*

*ព្រះពោធិសត្វទូលថា បពិត្រមហារាជ អាត្មាភាពមិនត្រូវការដោយវត្ថុកាមទេ អាត្មាសូមវត្ថុណា សូមទ្រង់ប្រទានតែវត្ថុនោះចុះ ដូច្នេះ លោកកាន់កម្រាលមានរូបផ្កាឈើជាប់គ្នាមួយ ស្បែកជើង និងឆត្រស្លឹកឈើ ហើយឲ្យឱវាទព្រះរាជាថា បពិត្រមហារាជ សូមព្រះអង្គកុំប្រមាទ ចូរឲ្យទាន រក្សាសីល និងធ្វើឧបោសថកម្មចុះ ។ កាលព្រះរាជាសូមអង្វរ ព្រះពោធិសត្វក៏ទៅព្រៃហិមពាន្តវិញ ។ ព្រះមហាសត្វញ៉ាំងអភិញ្ញា និងសមាបត្តិឲ្យកើតក្នុងព្រៃហិមពាន្តនោះឯង ហើយជាអ្នកមានព្រហ្មលោកជាទីទៅខាងមុខ ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា*

**តទា រាជា អានន្ទោ អហោសិ** *ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ*

**តាបសោ បន អហមេវ អហោសឹ** *ចំណែកតាបស គឺ តថាគតនេះឯង ។*

*ចប់ ព្រហ្មទត្តជាតក ៕*

( *ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត កុដិទូសកវគ្គ បិដកលេខ ៥៨ ទំព័រ ២១០* )

*ថ្ងៃ ពុធ ១០ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ៥ ខែ កញ្ញា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.រ.ថ.*